FARMER NOTES

# ព្រឹត្តិប័ត្រព័ត៌មានកសិករ



ការចេញផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
A Publication of the Cambodian Agricultural Research and Development Institute

# ជំងឺស្រូវ

## វិធីសាស្ត្រកំណត់អត្តសញ្ញាណជំងឺលើដំណាំស្រូវ

### ១.សេចក្តីផ្តើម

ជាទូទៅយើងដឹងថាស្រូវមានជំងឺ ដោយសាររូបភាពខាងក្រៅផ្លាស់ប្តូរខុសពីធម្មតា ។ សញ្ញាប្រែប្រួលខាងក្រៅ និងប្រតិកម្មខាងក្នុងស្រូវ ដែលបង្កឱ្យមានភាពប្រែប្រួលនោះ គឺគេហៅថា " រោគសញ្ញា " នៃជំងឺ ។

### ២.អត្តសញ្ញាណជំងឺលើដំណាំស្រូវ

ជាទូទៅ សញ្ញាប្រែប្រួលខាងក្រៅរបស់ស្រូវ អាចបញ្ជាក់ពីលក្ខណៈនៃប្រភេទជំងឺរបស់វាបាន ។ ប៉ុន្តែការកំណត់តាមរយៈការមើលនឹងភ្នែក វាមិនប្រាកដដល់ទៅ ១០០ ភាគរយនោះទេ ។ វាអាចយកជាការបាន ប្រសិនបើយើងមានបទពិសោធន៍ខ្ពស់ ឬមានការតាមដានទៅលើរោគសញ្ញា របស់វាឱ្យបានច្បាស់លាស់ត្រឹមត្រូវ ។

ជំងឺដែលបង្កឡើងដោយភ្នាក់ងារមានជីវិតដូចជា បង្កឡើងដោយពពួកផ្សិត បាក់តេរី វីរុស និងពពួកណេម៉ាតូត មានរោគសញ្ញាផ្សេងៗ ដូចជា រលួយគ្រាប់ រលាកស្រទបស្លឹក រលួយស្រទបស្លឹក រលួយគល់ រលួយឫស ក្រិន ដើមបែកច្រើនខុសពីធម្មតាតែគ្មានចេញកួរ រួញស្លឹកខ្លោចស្លឹក តឿដើម ថ្នាំងរញេៗ ឆ្នូតស្លឹក អុចគ្រាប់ អុចស្លឹក ក្រហមស្លឹក ប្រផេះស្លឹក ដើមធំខុសពីធម្មតា ស្រពោនស្លឹក លឿងស្លឹក ផ្ទុះគ្រាប់ តឿរួញស្លឹក ការបែកគុម្ពស្រូវ ថយចុះ រលួយបណ្តូលជាដើម ។

ជំងឺបង្កឡើងដោយភ្នាក់ងារគ្មានជីវិតដល់ដំណាំស្រូវ គឺ សីតុណ្ហភាព សំណើម ទឹកភ្លៀង ខ្យល់ ដី ការខ្វះ ឬការលើសសារធាតុចិញ្ចឹម ។ ជំងឺប្រភេទនេះមិនឆ្លងពីរុក្ខជាតិមួយទៅរុក្ខជាតិមួយ ឬពីតំបន់មួយទៅតំបន់មួយទៀតនោះទេ ។ រោគសញ្ញាសំគាល់នៃជំងឺទាំងនោះដូចជា ដំណុះគ្រាប់ខ្សោយ លូតលាស់ខ្សោយ សំណាបមានការប្រែពណ៌ សរីរាង្គលូតលាសម៉ានលក្ខណៈក្រិន វាបន្ថយកម្ពស់ និងទំហំដើម ការចេញកួរមិនពេញលេញ ពន្យាពេលចេញផ្កា បង្កើនចំនួនគ្រាប់ស្កក បែកគុម្ពតិច ស្រូវបង្កើនទម្ងន់ស្លឹក ដើមស្រូវដួល ការបន្តពូជពុំមានដំណើរការល្អ ។



